| ១០០ | កេន ញឹម | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១០១ | ឃីន កុន | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១០២ | កែវ កំសត់ | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១០៣ | ស ប៊ិន | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១០៤ | ទូន ចាន្ថា | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១០៥ | ឯក អ៊ឹម | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១០៦ | សុខ ផុន | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១០៧ | ទូន ជាក់ | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១០៨ | សុខ ធា | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០៩ | អ៊ិត ញាណ | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១១០ | អ៊ិត ហម | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១១១ | វ៉ៃ មឿន | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១១២ | ដុំ សាន | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១១៣ | វ៉ៃ ភឿន | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១១៤ | ខៃ សុកុល | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១១៥ | ខៃ សំអេន | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១១៦ | ណុប រិន | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១១៧ | សុត រឿន | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១១៨ | អ៊ុច ឈុំ | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១១៩ | មុជ ឃី | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១២០ | កេន ផែន | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |
| ១២១ | ម៉ៅ ហ៊ត | ប | ធ្វើស្រែ,នេសាទត្រី | កំពង់រទេះ | បឹងចារ | សំបូរ | ០៩/០៩/២០០៩ |

កំពង់រទេះ ថ្ងៃទី២៨..ខែ..មិថុនា..... ឆ្នាំ ២០១១

**ប្រធានសហគមន៍នេសាទ**

**ហត្ថលេខា**

[illegible]..ថ្ងៃទី១១..ខែកក្កដា..... ឆ្នាំ ២០១១

**បានឃើញ និង ឯកភាព**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទ កំពង់រទេះ

## ភូមិកំពង់រទេះ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ

| ល.រ | ឈ្មោះ | ភេទ | អាយុ | តួនាទី | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| ១ | ដួង សំអឿន | ប | ៣៧ | ប្រធានសហគមន៍ | ០៩២ ២៦៧ ៣៩២ |
| ២ | រស់ យីន | ស | ៥៥ | អនុប្រធាន | |
| ៣ | អ៊ីន វ៉ាន្នី | ស | ២៧ | លេខា | |
| ៤ | សរ គីមស៊ាន | ស | ៤១ | បេឡា | |
| ៥ | វ៉ែន ដុង | ស | ៣៦ | ក្រុមផ្សព្វផ្សាយ | ០៩២ ៨៣២ ០៥៤ |
| ៦ | ផុន ផាត | ប | ៣៣ | ក្រុមផ្សព្វផ្សាយ | |
| ៧ | អ៊ុំ ជាតិ | ប | ៣១ | ក្រុមល្បាត | ០១១ ៩៤៥ ៨២១ |
| ៨ | រស់ ធំ | ប | ៤១ | ក្រុមល្បាត | |
| ៩ | អ៊ុំ ឈិន | ប | ៣៨ | ក្រុមល្បាត | |

ធ្វើនៅកំពង់រទេះ,ថ្ងៃទី.០៣.....ខែវិច្ឆិកា.....ឆ្នាំ២០១១

ប្រធានគណៈកម្មការសហគមន៍នេសាទ

ហត្ថលេខា

ដួង សំអឿន

បានឃើញ និងបញ្ជាក់ថា

ឈ្មោះនៅក្នុងបញ្ជីខាងលើនេះគឺជាសមាជិកគណៈកម្មការ

សហគមន៍នេសាទកំពង់រទេះ ពិតប្រាកដមែន។

ធ្វើនៅ.បឹងចារ.ថ្ងៃទី..០៣.....ខែវិច្ឆិកា...ឆ្នាំ២០១១

មេឃុំ

ឃុំបឹងចារ

ហ៊ុល សឿន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រចនាសម្ព័ន្ធសហគមន៍នេសាទភូមិកំពង់រនេះ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ**

- **ប្រធាន**: លោក ដួង សំអឿន
  - **ក្រុមទីប្រឹក្សា**
    - លោក មេឃុំបឹងចារ
    - ចាស់ទុំក្នុងភូមិកំពង់រនេះ
    - លោក មេភូមិកំពង់រនេះ
    - ប៉ូលិសប៉ុស្តិ៍
    - ខណ្ឌរដ្ឋបាលជលផលក្រចេះ
  - **អនុប្រធាន**: លោកស្រី រស់ យើន
    - **បេឡាធិការ**: លោកស្រី សរ គីមស៊ាន
    - **លេខាធិការ**: លោកស្រី អ៊ុន ថាវី
    - **អប់រំផ្សព្វផ្សាយ**
      - លោកស្រី វ៉េន ដុង
      - លោក ផុន ផាត
    - **ផ្នែកល្បាត**
      - លោក អ៊ុំ ជាតិ
      - លោក រស់ ធំ
      - លោក អ៊ុំ ឈិន

**តួនាទី និងភារកិច្ចទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ**

**១-ប្រធានគណៈកម្មការសហគមន៍នេសាទ**

-ដឹកនាំ និងទទួលខុសត្រូវរួមក្នុងការអនុវត្តន៍ការងារនៅក្នុងសហគមន៍នេសាទ

-សម្របសម្រួលជាមួយស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន ដើម្បីគាំទ្រដល់ការងារសហគមន៍នេសាទ

-ទំនាក់ទំនងជាមួយអង្គការនានា ដើម្បីស្វែងរកជំនួយទ្រទ្រង់សកម្មភាពសហគមន៍នេសាទ

-សម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗក្នុងសហគមន៍នេសាទ

-តាមដានត្រួតពិនិត្យរាល់សកម្មភាពការងាររបស់សហគមន៍នេសាទ

-ដឹកនាំរាល់ការប្រជុំ និងមហាសន្និបាតក្នុងការបូកសរុបវាយតម្លៃ និងរៀបចំផែនការការងារ

-ផ្តល់ភាពយុត្តិធម៌ និងតម្លាភាពដល់សមាជិកសហគមន៍ ។

**២-អនុប្រធានគណៈកម្មការសហគមន៍នេសាទ**

-ចូលរួមអនុវត្តន៍ការងារជាមួយប្រធាន

-ជំនួសមុសឱ្យប្រធាននៅពេលអវត្តមាន

-អនុប្រធានទី១ទទួលបន្ទុកផ្នែកបេឡាធិការ និងអប់រំផ្សព្វផ្សាយ

-អនុប្រធានទី២ ទទួលបន្ទុកផ្នែកលេខាធិការ និងក្រុមល្បាត

-ទទួលភារកិច្ចផ្សេងៗ ដែលប្រធានប្រគល់ជូន

**៣.លេខាធិការ**

-កត់ត្រារាល់សកម្មភាព និងរក្សាទុកដាក់ឯកសារផ្សេងៗរបស់សហគមន៍នេសាទ

-ធ្វើកំណត់ហេតុរាល់ការប្រជុំ និងមហាសន្និបាត របស់សហគមន៍នេសាទ

-រៀបចំលិខិតអញ្ជើញ និងទីកន្លែងប្រជុំ

-ទទួលពាក្យស្នើសុំចូលជាសមាជិក និងការលាលែងពីសមាជិក

-កត់ត្រា និងគ្រប់គ្រងសម្ភារៈរបស់សហគមន៍

-រៀបចំបែបបទ និងលិខិតស្នាមផ្សេងៗ ដែលទាក់ទងការគ្រប់គ្រងសហគមន៍នេសាទ

-ទទួលពាក្យបណ្ដឹងតវ៉ាផ្សេងៗ

-ព្រាងរបាយការណ៍ពីលទ្ធផលការងាររបស់សហគមន៍នេសាទ ដើម្បីដាក់ជូនប្រធានពិនិត្យ និងសម្រេច។

**៤.ហេរញ្ញិការ**

-ទទួលខុសត្រូវការងារហិរញ្ញវត្ថុរបស់សហគមន៍នេសាទទាំងមូល

-គ្រប់គ្រង និងចុះបញ្ជីគណនេយ្យរបស់សហគមន៍ឱ្យបានត្រឹមត្រូវតាមប្រព័ន្ធការងារគណនេយ្យ

-រៀបចំគម្រោងផែនការប្រើប្រាស់ហិរញ្ញវត្ថុរបស់សហគមន៍ ដើម្បីគណៈកម្មការពិនិត្យ និងសម្រេច

-ធ្វើរបាយការណ៍ និងរាយការពីស្ថានភាពចំណូល-ចំណាយ ជូនគណៈកម្មការសហគមន៍ជារាងរាល់ខែ

-ស្នើសុំការឯកភាពពីសមាជិកគណៈកម្មការសហគមន៍នេសាទ នូវរាល់ចំណាយផ្សេងៗ និងរក្សាទុកដាក់ឯកសារឱ្យបានត្រឹមត្រូវ

-រៀបចំបែបបទ និងទទួលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំពីសមាជិក។

**៥.ផ្នែកអប់រំ ផ្សព្វផ្សាយ**

-អប់រំផ្សព្វផ្សាយ ពីខ្លឹមសារលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍ ច្បាប់ អនុក្រឹត្យ សេចក្ដីជូនដំណឹង និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធលើការគ្រប់គ្រងវិស័យជលផល បរិស្ថាន សិទ្ធិមនុស្ស អនាម័យ និងសុខភាព .ល. ជូនដល់សមាជិកសហគមន៍របស់ខ្លួន និងសហគមន៍នេសាទជិតខាង។

-ស្វែងរកវិធីសាស្ត្រ និងបទពិសោធន៍ល្អៗ សម្រាប់ធ្វើការអប់រំ ផ្សព្វផ្សាយឱ្យរឹតតែមានប្រសិទ្ធភាព

-រៀបចំឯកសារ ផ្ទាំងសញ្ញា និងរូបភាពផ្សេងៗសម្រាប់ធ្វើការអប់រំផ្សព្វផ្សាយ

-រៀបចំវគ្គបណ្ដុះបណ្ដាល ទស្សនៈកិច្ចសិក្សា ដើម្បីលើកកំពស់ការយល់ដឹង និងផ្លាស់ប្ដូរបទពិសោធន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ

-ធ្វើរបាយការណ៍ពីលទ្ធផលលើការងារអប់រំ និងវាយតម្លៃផែនការអនុវត្តន៍ ជូនប្រធានគណៈកម្មការសហគមន៍នេសាទជារាងរាល់ខែ។

**៦.ផ្នែកល្បាត**

-ទទួលខុសត្រូវលើកិច្ចការការពារធនធានជលផល និងទប់ស្កាត់បទល្មើស ដែលកើតមាននៅក្នុងដែននេសាទសហគមន៍

-ទទួលបន្ទុកពិនិត្យ តាមដាន ឃ្លាំមើល និងល្បាតនូវរាល់សកម្មភាពនេសាទ។ ករណីចាំបាច់ត្រូវរាយការណ៍ព័ត៌មានជូនប្រធានឱ្យបានឆាប់រហ័ស

-សហការណ៍ជាមួយសមត្ថកិច្ចជលផល បង្ក្រាបរាល់បទល្មើសជលផល នៅក្នុងកន្លែងនេសាទសហគមន៍។ ក្នុងករណីបន្ទាន់ និងចាំបាច់ផ្នែកល្បាតសហគមន៍នេសាទអាចស្នើសុំអន្តរាគមន៍ពីសមត្ថកិច្ចនៅជិតបំផុត អាជ្ញាធរ ដែនដីដើម្បីឃាត់ទុកវត្ថុតាងនៃបទល្មើស និងឃាត់ខ្លួនជនល្មើស រួចបញ្ជូនជាបន្ទាន់ទៅសមត្ថកិច្ចជលផល ដើម្បីធ្វើការដោះស្រាយបទល្មើសទៅតាមច្បាប់

-រៀបចំផែនការល្បាត និងចាត់វិធានការការពារធនធានធម្មជាតិក្នុងតំបន់គ្រប់គ្រង ដើម្បីអនុវត្តន៍ឱ្យមានប្រសិទ្ធិភាព

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលសកម្មភាពអនិវត្តការងាររបស់ខ្លួន ជូនប្រធានគណៈកម្មការសហគមន៍នេសាទជារៀងរាល់ខែ។

## ៧-តួនាទីក្រុមទីប្រឹក្សា

-ផ្តល់បទអន្តរាគមន៍ចំពោះបទល្មើសជលផលដែលហួសសមត្ថភាពសមាជិកសហគមន៍

-ជួយជ្រោមជ្រែង និងគាំទ្រដល់សកម្មភាពល្បាតរបស់សហគមន៍ តាមរយៈក្រុមល្បាត

-រុះរើ ឬរៀបចំឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រងរបស់សហគមន៍ ការពារគោលដៅរបស់សហគមន៍

-កោះប្រជុំសហគមន៍ ប្រសិនបើចាំបាច់

-បំពេញកិច្ចការផ្សេងទៀត ដែលសហគមន៍លើកឡើង

ធ្វើនៅភូមិកំពង់រទេះ, ថ្ងៃទី...០៣...ខែមីនា...ឆ្នាំ ២០១១.

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**សត្ថលេខា**

ឡុង ឥណ្ឌឿន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ៤-លក្ខន្តិកៈ

# សហគមន៍នេសាទកំពង់រទេះ

# ភូមិកំពង់រទេះ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ

| | | |
|---|---|---|
| ឈ្មោះសហគមន៍ | : | កំពង់រទេះ |
| ភូមិ | : | កំពង់រទេះ |
| ឃុំ | : | បឹងចារ |
| ស្រុក | : | សំបូរ |
| ខេត្ត | : | ក្រចេះ |

## ជំពូកទី ១
## គោលបំណង និងនាមករណ៍

**ប្រការ ១.–**

លក្ខន្តិកៈនេះមានគោលបំណង ៖

- កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានជលផលរបស់សហគមន៍ប្រកបដោយនិរន្តរភាព
- ធ្វើជាគោលការណ៍គ្រឹះ និងជាយន្តការសម្រាប់ដំណើរការសហគមន៍
- ការពារសិទ្ធិ និងផលប្រយោជន៍របស់សមាជិកសហគមន៍ និងផលប្រយោជន៍ជាសាធារណៈ ។

**ប្រការ ២.–**

ឈ្មោះសហគមន៍នេសាទ**កំពង់រទេះ** ហៅកាត់ថា **ស.ហ.គ.ក.ព.រ.ទ** មានអាស័យដ្ឋានមនៅ ភូមិ **កំពង់រទេះ** ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ ។

សហគមន៍នេសាទនេះមានការចូលរួមពីប្រជាពលរដ្ឋដែលរស់ក្នុង ៖

១. ភូមិ **កំពង់រទេះ** ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ

**មានកម្មវត្ថុ:** ដើម្បីរួមចំណែកគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានជលផលឱ្យមាននិរន្តរភាព ដោយរាប់បញ្ចូលការទប់ស្កាត់បទល្មើសជលផល ។

## ជំពូកទី ២
## លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភារកិច្ច និងសិទ្ធិរបស់សមាជិក

**ប្រការ ៣.–**

ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងចង់ចូលជាសមាជិកសហគមន៍អភិរក្ស មានសិទ្ធិដាក់ពាក្យសុំចូលដោយស្ម័គ្រចិត្ត និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

- មានលំនៅដ្ឋាននៅក្នុងបណ្តាភូមិនៃសហគមន៍
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ

**ប្រការ ៤.–**

សមាជិកសហគមន៍ ដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ៣ខាងលើ មានសិទ្ធិ ៖

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោត និងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍ស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេះ

- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ច សង្គមរបស់សហគមន៍ពីគណៈកម្មការសហគមន៍
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍ទាំងអស់
- ធ្វើនេសាទជាលក្ខណៈគ្រួសារស្របតាមច្បាប់ស្តីពីជលផលកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ផែនការគ្រប់គ្រង កន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធវិស័យជលផល
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍
- ប្តឹងតវ៉ា ឬ ផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅ សមត្ថកិច្ចរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ
- ទទួលការគាំទ្រពីមជ្ឈដ្ឋាននានា ដើម្បីផលប្រយោជន៍របស់សហគមន៍ ។

សមាជិកសហគមន៍ត្រូវទទួលខុសត្រូវរាល់សកម្មភាពរៀង១ខ្លួន និងរួមគ្នាចំពោះកំហុសដែលខ្លួនបាន ប្រព្រឹត្តក្នុងពេល បំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់ (១/១០) ឡើងទៅអាចស្នើសុំឱ្យប្រធានគណៈកម្មការ សហគមន៍បញ្ចូលបញ្ហាមួយចំនួន ក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់គណៈកម្មាការសហគមន៍សាមុី ហើយចំនួនសមាជិក សហគមន៍ដែលបានស្នើរសុំខាងលើនេះអាចចាត់តំណាងចំនួនបី (៣) នាក់ ចូលរួមប្រជុំ ដើម្បីចោទសួរគណៈកម្មការ សហគមន៍នូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងចំណុចដែលបានស្នើឡើងនោះ ។

**ប្រការ ៥.–**

សមាជិកសហគមន៍មានកាតព្វកិច្ច និងភារកិច្ចដូចខាងក្រោម ÷

- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល
- អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- អនុវត្តតាមអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែមិនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងលិខិតបទដ្ឋានផ្សេង១ទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ
- អនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍ដើម្បីផលប្រយោជន៍ និងការរីកចំរើនរបស់សហគមន៍
- ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍
- ចូលរួមឃ្លាំមើល ទប់ស្កាត់ និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍ ។

# ជំពូកទី ៣

## លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិក

**ប្រការ ៦._**

សមាជិកសហគមន៍ មានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ ÷

- ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ
- ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ ៧._**

សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាព ក្នុងលក្ខខណ្ឌដូចខាងក្រោម ÷

- ការមិនបង់ភាគទានចំនួន៣លើកជាប់ៗគ្នា
- ការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃសហគមន៍ ឬសមាជិកសហគមន៍អភិរក្ស ដទៃទៀត
- សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម
- សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

# ជំពូកទី ៤

## របៀបរបបកាន់បញ្ជី និង ឯកសារនានា

**ប្រការ ៨._**

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍បានមកពី ÷

- ភាគទានរបស់សមាជិកសហគមន៍
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
- ចំណូលស្របច្បាប់ផ្សេងៗទៀត ។

**ប្រការ ៩._**

**រាល់ការចំណាយថវិកា សហគមន៍ត្រូវអនុវត្តន៍ដូចតទៅ :**

**-ការចំណាយ ពី ១ 00 ៛ ដល់ ៤០ 000 ៛ ត្រូវសំរេចដោយប្រធានសហគមន៍នេសាទ**

**-ការចំណាយ ពី ៤០ 000 ៛ ដល់ ១៥០ 000 ៛ ត្រូវសំរេចដោយគណៈកម្មការសហគមន៍នេសាទ**

**-ការចំណាយ ពី ១៥០ 000 ៛ ឡើងទៅត្រូវសំរេចដោយមហាសន្និបាទ**

**ប្រការ ១០.–**

សហគមន៍ត្រូវតម្កល់ទុកឯកសារ និងរៀបចំឱ្យមានបញ្ជី ÷

-ការគ្រប់គ្រងថវិកា ត្រូវមានការកាន់បញ្ជីគណនេយ្យ

-ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍

-រាល់ថវិការចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីបត្រ និងចុះបញ្ជីឱ្យបានត្រឹមត្រូវ

-ថវិការដែលត្រូវចំណាយ គឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្ស និង អភិវឌ្ឍសហគមន៍

## ជំពូកទី ៥
## គណៈកម្មការសហគមន៍

**ប្រការ ១១.–**

សមាសភាពគណៈកម្មការសហគមន៍រួមមាន ប្រធាន អនុប្រធាន និងសមាជិក។ គណៈកម្មការសហគមន៍ ត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុកហិរញ្ញិកមួយរូប និងត្រូវពិភាក្សា បែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង។

ប្រធានគណៈកម្មការសហគមន៍ ទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងសហគមន៍ទាំងមូល។ អនុប្រធានគណៈកម្មការសហគមន៍ ជាជំនួយការឱ្យប្រធាន។

**ប្រការ ១២.–**

គណៈកម្មការសហគមន៍មានអាណត្តិប្រាំ (៥) ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែល មានគណៈកម្មការសហគមន៍ថ្មីត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតឱ្យចូលកាន់តំណែងជំនួស។ ក្នុងករណីដែលសហគមន៍ដំណើរការមិនប្រក្រតី ដោយមូលហេតុដំណើរការមិនល្អ ឬអសមត្ថភាពក្នុងការគ្រប់គ្រងសហគមន៍ សមាជិកសហគមន៍ចំនួនមួយភាគបី (១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញ ដើម្បីបោះឆ្នោតជ្រើស រើសគណៈកម្មការសហគមន៍ជាថ្មី ។

**ប្រការ ១៣.–**

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍ណាម្នាក់អវត្តមាន ដោយគ្មានមូលហេតុរយៈពេល ប្រាំមួយ (៦)ខែ ឬសុំលាលែងមុនចប់អាណត្តិ បេក្ខជនដែលមានឈ្មោះតាមសម្លេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោត ជ្រើសរើសក្នុង មហាសន្និបាតកន្លងមក ត្រូវបានជ្រើសតាំងជំនួស។

## ជំពូកទី ៦
## របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍

**ប្រការ ១៤.–**

គណៈកម្មការសហគមន៍អភិរក្សត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ។កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍ អាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន ២/៣ (ពីរភាគបី) នៃសមាសជិករបស់គណៈកម្មការសហគមន៍ ទាំងមូល។

**ប្រការ ១៥.–**

ប្រធានគណៈកម្មការសហគមន៍ ជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានរាល់កិច្ចប្រជុំ ។ ក្នុងករណីប្រធាន គណៈកម្មការសហគមន៍ អវត្តមាន អនុប្រធានដែលត្រូវបានប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ ។ រាល់ការប្រជុំ ត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់។

ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍ប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យ មានរបៀបរៀបរយ និងគ្មានការរំខាន ។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះធ្វើឱ្យខូចសណ្តាប់ ធ្នាប់អង្គប្រជុំ ។

**ប្រការ ១៦ .–**

ការសម្រេចលើបញ្ហាណាមួយរបស់សហគមន៍ ដូចមានចែងខាងក្រោមនេះ គឺត្រូវអនុម័តដោយកិច្ចប្រជុំរបស់ គណៈកម្មការសហគមន៍ដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការសហគមន៍ដែលមានវត្តមានក្នុងអង្គប្រជុំ ។ ក្នុងករណីដែលមានសំលេងស្មើគ្នា មតិប្រធានអង្គប្រជុំជាឧត្តមានុភាព ÷

- សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍
- ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍ ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានគណៈកម្មការសហគមន៍ ត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិក សហគមន៍អំពីសេចក្តីសម្រេចរបស់ខ្លួន ។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍ ត្រូវបិទ ផ្សាយជាសាធារណៈ នៅទីស្នាក់ការសហគមន៍ ឬសាលាឃុំ សង្កាត់ យ៉ាងយូរ ក្នុងរយៈពេល៧ថ្ងៃ បន្ទាប់ពីការប្រជុំ ។

## ជំពូកទី ៧

## មហាសន្និបាតសហគមន៍

**ប្រការ ១៧.–**

មហាសន្និបាតសហគមន៍ ជាអង្គប្រជុំកំពូលដើម្បីធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចទាំងឡាយក្នុងនាមសហគមន៍ ។ មហាសន្និបាតកំណើតដំបូងរបស់សហគមន៍ត្រូវប្រារព្ធធ្វើឡើង បន្ទាប់ពីក្រុមស្ថាបនិក បានរៀបចំរួចរាល់ នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត ។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពី សមាជិកដែលបានដាក់ពាក្យស្នើសុំរួចមកហើយ ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍ អនុម័តនូវសេចក្តីសម្រេច និងកិច្ចការសំខាន់ដូចខាង ក្រោម ÷

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍
- ឈ្មោះសហគមន៍
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍

- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍

**ប្រការ ១៨.-**

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង ១ ឆ្នាំម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍។ ក្នុងករណីចាំបាច់ សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញ តាមការស្នើសុំពីសមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) យ៉ាងតិច។

**ប្រការ ១៩.-**

គណៈកម្មការសហគមន៍ អាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍ ។

**ប្រការ ២០.-**

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម ÷

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅសាលាឃុំសង្កាត់ និងទីស្នាក់ការសហគមន៍នេសាទ
- ការកោះអញ្ជើញសមាជិកសហគមន៍ឱ្យចូលរួមមហាសន្និបាតសាមញ្ញត្រូវធ្វើឡើងដប់ (១០) ថ្ងៃ យ៉ាងតិចមុនថ្ងៃបើកមហាសន្និបាត និងបី (៣) ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ
- មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញអាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍
- អង្គប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការសហគមន៍ ឬ ប្រធានអង្គប្រជុំដែលជ្រើសរើស ដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន
- មហាសន្និបាតត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្តីសម្រេច និងបញ្ជីវត្តមាន
- លេខាកត់ត្រា និងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្តីសម្រេចរបស់មហាសន្និបាត ត្រូវយកសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកដែលមាន វត្តមាន។

**ប្រការ ២១.-**

មហាសន្និបាតអនុម័ត ÷

- សេចក្តីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី៣ នៃលក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងអភិរក្សសហគមន៍
- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍
- ការសុំលាលែង ឬការបណ្តេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍
- គម្រោងចំណូល ចំណាយរបស់សហគមន៍

## ជំពូកទី ៨
## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍

**ប្រការ ២២.-**

ចំនួនសមាជិកគណៈកម្មការសហគមន៍ និងចំនួនបេក្ខជនឈរឈ្មោះត្រូវអនុម័តដោយមហាសន្និបាត ។

**ប្រការ ២៣.-**

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍ គឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការ បោះឆ្នោត ដែលអនុម័តដោយមហាសន្និបាត ។ គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាពពីបី (៣) ទៅប្រាំ (៥) នាក់ ដែលមានប្រធាន អនុប្រធាន និងសមាជិក តាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាត និងត្រូវមានលក្ខណៈ សម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង និងមានសីលធម៌ល្អ ។ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាព ស្មោះត្រង់ ។

**ប្រការ ២៤.-**

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ចដូចខាងក្រោម ÷

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត
- បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតីដើម្បីប្រកាសជូនមហាសន្និបាត
- ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផល បោះឆ្នោតចប់ជាស្ថាពរ ។

**ប្រការ ២៥.-**

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍ ។ បេក្ខជន ដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ត្រូវទទួលតួនាទីជាអនុប្រធាន ជាសមាជិកគណៈកម្មការសហគមន៍អភិរក្ស តាមលំដាប់ លំដោយ ។ ក្នុងករណីបេក្ខជនដែលមានសំឡេងគាំទ្រស្មើគ្នា ត្រូវជ្រើសរើសស្ត្រី ឬបោះឆ្នោតរកអ្នកដែល មានសមត្ថភាព ដោយលើកដៃយកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍ ដែលចូលរួម ។

## ជំពូកទី ៩
## លក្ខខណ្ឌនៃការរំសាយសហគមន៍ និង នីតិវិធីដោះស្រាយវិវាទ

**ប្រការ ២៦.-**

ការរំសាយសហគមន៍នេសាទត្រូវផ្អែកតាម ÷

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀង កន្លែង អភិរក្ស សហគមន៍

- សេចក្តីសម្រេចមហាសន្និបាត

- ក្រោយពីរំសាយសហគមន៍ ទ្រព្យសម្បត្តិរបស់សហគមន៍ ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាត លើកលែងតែដែនទេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ ។

**ប្រការ ២៧.–**

ក្នុងករណីមានការតវ៉ា ឬ ចោទថាដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទមានភាពមិនប្រក្រតីអ្នកតវ៉ាត្រូវបង្ហាញ ភស្តុតាងឱ្យបាន ច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាម នៅមុនពេលប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាត ពិនិត្យ និងសម្រេច។

**ប្រការ ២៨.–**

វិវាទទាំងឡាយនៅក្នុងសហគមន៍ ត្រូវដោះស្រាយដូចខាងក្រោម ÷

-គណៈកម្មការសហគមន៍ត្រូវសម្រុះសម្រួលនិងដោះស្រាយរាល់វិវាទដែលកើតមានឡើងនៅក្នុង សហគមន៍របស់ខ្លួន

-ក្នុងករណីគណៈកម្មការសហគមន៍ដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះ ទៅសមត្ថកិច្ចរដ្ឋបាលជលផលដើម្បីដោះស្រាយទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់។

-ក្នុងករណីដែលបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍ និងរដ្ឋបាលជលផល ត្រូវបញ្ជូនសំណុំរឿងទៅតុលាកាខេត្ត ក្រុងសាមី ដើម្បីដោះស្រាយតាមផ្លូវច្បាប់។

**ប្រការ ២៩.–**

សមាជិកសហគមន៍រូបណាដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេះត្រូវទទួលទណ្ឌកម្មពីគណៈកម្មការសហគមន៍ ឬមហាសន្និបាតសហគមន៍ ទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន ។

## ជំពូកទី ១០

## នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍

**ប្រការ ៣០.–**

ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ ត្រូវសម្រេចដោយមហាសន្និបាត។ ការលើកសំណើរកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ត្រូវធ្វើឡើង ដោយសមាជិកយ៉ាងតិចមួយភាគបី(១/៣) នៃសមាជិកសហគមន៍ទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែមុនបើកមហាសន្និបាត ។ លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបានលុះត្រាតែមានសំលេងយល់ព្រមលើសពីពាក់កណ្តាលនៃ សមាជិក មហាសន្និបាត សហគមន៍។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**ប្រការ ៣១.–**

លក្ខន្តិកៈសហគមន៍នេះត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍លើកដំបូង នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៩ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍ ។

ធ្វើនៅ **កំពង់រទេះ** .ថ្ងៃទី១៥.. ខែ.កក្កដា...ឆ្នាំ ២០០៩.

**ប្រធានគណៈកម្មការសហគមន៍**

ឡឹម សាឡឿន

បឹងចារ.ថ្ងៃទី០៣.ខែ.ធ្នូ...ឆ្នាំ ២០១១

**បានឃើញ និង ឯកភាព**

ហ៊ុល–ស្មឿន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ៥~បញ្ញាផ្ទៃក្នុង

# សហគមន៍នេសាទកំពង់រទេះ

# ភូមិកំពង់រទេះ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ

| | | |
|---|---|---|
| ឈ្មោះសហគមន៍ | : | កំពង់រទេះ |
| ភូមិ | : | កំពង់រទេះ |
| ឃុំ | : | បឹងចារ |
| ស្រុក | : | សំបូរ |
| ខេត្ត | : | ក្រចេះ |

## បទបញ្ជាផ្ទៃក្នុងសហគមន៍

ដើម្បីធានាការគ្រប់គ្រងសហគមន៍ឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយល្អ សហគមន៍នេសាទ សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម ៖

**ប្រការ ១.–**

គណៈកម្មការ និងសមាជិកគ្រប់រូបនៃសហគមន៍នេសាទ ត្រូវមានភាពស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុង ជួយស្ថាបនា និងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចម្រើនរបស់សហគមន៍ ។

**ប្រការ ២.–**

គណកម្មការ សមាជិកសហគមន៍ ឬ បុគ្គលណាដែលបានកេងប្រវ័ញ្ចធ្វើឱ្យខូចខាត ឬ បាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ ៖

-ចំពោះសមាជិកសហគមន៍ ឬបុគ្គលដទៃទៀតត្រូវសង ឬ ទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្តែង តាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍។ ក្នុងករណីមិនព្រមសង ត្រូវដាក់ជូនមហាសន្និបាតសម្រេច។

-ចំពោះគណៈកម្មការសហគមន៍ត្រូវសង ឬ ទូទាត់សងការខូចខាតតាមការសម្រេចរបស់មហាសន្និបាត ។ ប្រសិនបើនីតិវិធីខាងលើនេះនៅតែមិនអាចដោះស្រាយបាន គឺត្រូវអនុវត្តតាមផ្លូវច្បាប់ និងបទបញ្ជាជាធរមាន។

**ប្រការ ៣ .–**

សមាជិកគ្រប់រូបនៃសហគមន៍ ត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍ តាមការកោះអញ្ជើញរបស់ប្រធានសហគមន៍។ ក្នុងករណីដែលសមាជិកណាម្នាក់មិនបានមកចូលរួមប្រជុំចំនួន ៣ ដងជាប់ៗគ្នាដោយគ្មាន មូលហេតុច្បាស់លាស់ត្រូវទទួលការណែនាំពីគណកម្មការសហគមន៍។ ករណីនៅតែមិនរាងចាលគណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់សមាជិកភាព នៃសមាជិកសាមីរូបនោះ ។

**ប្រការ ៤.–**

សិទ្ធិដាក់ទណ្ឌកម្ម ៖

**ក -គណកម្មការសហគមន៍**

- អប់រំណែនាំលើកទី១ លើកទី២ និងលើកទី៣
- ព្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍
- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផល ចំពោះការនេសាទលើសទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំងតាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងនៅក្នុងកន្លែងនេសាទសហគមន៍ ។

**ខ-មហាសន្និបាត**

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ ៧ នៃលក្ខន្តិកៈសហគមន៍
- សម្រេចលើសំណងការខូចខាតទ្រព្យសម្បត្តិសហគមន៍
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការសហគមន៍ ចំពោះបទល្មើសរបស់ពួកគេ
- ដាក់ទណ្ឌកម្មដល់សមាជិក ឬបុគ្គលដទៃ ដែលគណៈកម្មការមិនអាចដោះស្រាយបាន ។

**ប្រការ ៥.–**

សមាជិកគ្រប់រូបនៃសហគមន៍នេសាទ ត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍ និង/ឬក្រុមទីប្រឹក្សា អំពីសំភារៈ និងឧបករណ៍នេសាទ ដែលគ្រួសារនីមួយៗប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ។

**ប្រការ ៦.–**

សហគមន៍នេសាទជាសមាជិក អាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារនៅក្នុងរដូវបើកនេសាទ ដូចមានចែងខាងក្រោម ÷

| ល.រ | ឈ្មោះឧបករណ៍នេសាទ | ក្រឡា/ទំហំ | ចំនួន/ប្រវែង |
|---|---|---|---|
| ១ | ថ្នង | មិនលើស២ ម៉ែត្រ | ១ |
| ២ | សំណាញ់ | ២,៥ ស.ម- ៣ ស.ម | ១២ ហាត់ |
| ៣ | សន្ទូចបង្កៃ | ២០០ | ផ្លៃ |
| ៤ | លាន់ | ២០ | ២០ លាន់ |
| ៥ | អង្រុត | ១ | ១អង្រុត |
| ៦ | ទ្រូ( ទ្រូកំពឹស) | ៥ | ៥ទ្រូ |
| ៧ | ឈ្នាង | ១ | ១ ឈ្នាង |
| ៨ | លប | ៥ | ៥ លប |
| ៩ | ច្បូក/ស្នូរ | ១ | ១ច្បូក/ស្នូរ |
| ១០ | កញ្ច្រែង | ២ | ២ កញ្ច្រែង |
| ១១ | លាយ | ២ | ២ លាយ |
| ១២ | ចាន់ | ១៥ | ១៥ |

**ចំណាំ :**

**១**-ចំពោះឧបករណ៍ដែលមិនមានក្នុងតារាង គឺជាឧបករណ៍ខុស និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ មិនអាចនេសាទបានទេ ។

**២** -ចំពោះឧបករណ៍ ច្បូក/ស្នូរ មិនអាចនេសាទបាននៅពេលយប់ ព្រោះជាឧបករណ៍ខុសច្បាប់ ។

**៣**-ចំពោះ កន្លែងអភិរក្សសហគមន៍ សមាជិក ឬ គណៈកម្មការ ពុំមានសិទ្ធិនេសាទឡើយ ។

៤-ចំពោះអ្នកនេសាទនៅក្នុងដែនអភិរក្សរបស់សហគមន៍ត្រូវទទួលទុសតាមច្បាប់

**ប្រការ ៧.-**

សមាជិកសហគមន៍នេសាទ ដែល ÷

-ប្រព្រឹត្តផ្ទុយ ឬរារាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចក្នុងប្រការ៥ នៃលក្ខន្តិកៈ ត្រូវព្យួរសមាជិកភាពដោយគណៈកម្មការសហគមន៍ ឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាតសហគមន៍ ។

-មិនចូលរួមថែរក្សាការពារធនធានជលផល ឬមិនរាយការណ៍អំពីសកម្មភាពបទល្មើសជលផល ត្រូវព្រមានដោយគណៈកម្មការសហគមន៍ ។

-ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ កាប់ឆ្ការ រានព្រៃលិចទឹក វាតយកដីក្នុងដែននេសាទ សហគមន៍ ឬធ្វើអោយខូចដល់ប្រព័ន្ធបរិស្ថាននេសាទ ត្រូវទទួលការផ្តន្ទាទោសតាម ច្បាប់ស្តីពីជលផល ។

-ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច ។

-អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែង នេសាទសហគមន៍ ត្រូវផ្អាកការនេសាទ ទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ជូនទៅរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីដោះស្រាយតាមច្បាប់ ។

**ប្រការ៨.-**

ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍ អាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនពត៌មានដល់គណៈកម្មការសហគមន៍នេសាទសាមី ហើយធ្វើកិច្ចសន្យា និងគោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទ សហគមន៍ ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបានគោរពតាមប្រការនេះ គណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំណែនាំ។

**ប្រការ ៩.-**

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយសន្និបាតរបស់សហគមន៍ នៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០០៩ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណៈកម្មការសហគមន៍តទៅ ។

ធ្វើនៅ **កំពង់រនេះ** ,ថ្ងៃទី០៥.... ខែកញ្ញា ឆ្នាំ២០០៩

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**ហត្ថលេខា**

ស៊ួន សាលឿង

បឹងចារ,ថ្ងៃទី០៣..ខែ...... ឆ្នាំ ២០១១

**បានឃើញ និង ឯកភាព**

ឃុំ បឹងចារ

ហ៊ុល_សឿន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ៦_សេចក្តីថ្លែងការណ៍

# នៃការបង្កើតសហគមន៍នេសាទកំពង់រទេះ

# ភូមិកំពង់រទេះ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ

| | | |
|---|---|---|
| ឈ្មោះសហគមន៍ | : | កំពង់រទេះ |
| ភូមិ | : | កំពង់រទេះ |
| ឃុំ | : | បឹងចារ |
| ស្រុក | : | សំបូរ |
| ខេត្ត | : | ក្រចេះ |

# សេចក្តីថ្លែងការណ៍

យើងខ្ញុំជាគណៈកម្មការសហគមន៍នេសាទ**កំពង់រទេះ** ដែលបានបង្កើតនៅក្នុងឆ្នាំ ២០០០ ក្រោយការឧបត្ថម្ភបច្ចេកទេសដោយខណ្ឌរដ្ឋបាលជលផលក្រចេះ និងមានការគាំទ្រថវិការដោយអង្គការអុស្វាមអូស្រ្តាលី ។

យើងខ្ញុំសូមជំរាបជូនលោកនាយខណ្ឌរដ្ឋបាលជលផលមេត្តាជ្រាបថា ការផ្តួចផ្តើមបង្កើតសហគមន៍នេសាទបានកើតឡើងក្រោយពីមានសំណូមពររបស់ប្រជាពលរដ្ឋ និងដោយមានគោលនយោបាយកែទម្រង់វិស័យជលផលរបស់រាជរដ្ឋាភិបាលនៅខែ តុលា ឆ្នាំ ២០០០ មកធ្វើឱ្យប្រជាពលរដ្ឋភូមិ **កំពង់រទេះ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ** បានព្រមព្រៀងគ្នាបង្កើតសហគមន៍នេសាទក្នុងគោលបំណងចូលរួមចំណែក គ្រប់គ្រង ការពារ ប្រើប្រាស់ និងអភិរក្ស ដែនសហគមន៍នេសាទឱ្យមាននិរន្តរភាព ។

ចាប់តាំងពីបានបង្កើតសហគមន៍នេសាទក្នុងឆ្នាំ ២០០៩ រហូតមកដល់សព្វថ្ងៃ គឺយើងខ្ញុំបានខិតខំប្រឹងប្រែង ធ្វើការសំខាន់ៗ និងសហការយាមល្បាត បង្ក្រាបបទល្មើសនេសាទ ទប់ស្កាត់ការពង្រីកដីកសិកម្ម បង្កើតកន្លែងអភិរក្ស ជលផល និងអភិវឌ្ឍន៏សហគមន៍នេសាទ ។

ទន្ទឹមនឹងនេះ សហគមន៍នេសាទយើងខ្ញុំបានរៀបចំរួចរាល់នូវឯកសារសំរាប់ការបង្កើតកិច្ចព្រមព្រៀង កន្លែង នេសាទសហគមន៍ដូចដែលមានចែងនៅក្នុងមាត្រា ៧ ជំពូក ២ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងដែលសហគមន៍នេសាទ ដែលរួមមានបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង និងផែនទីកន្លែងនេសាទសហគមន៍ ។

ដោយផ្អែកលើសមិទ្ធិផលដូចបានរៀបរាប់ខាងលើ និងការសំរេចរបស់មហាសន្និបាទដែលបានប្រារព្ធធ្វើនៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០៩ យើងខ្ញុំគណៈកម្មការតំណាងឱ្យសហគមន៍នេសាទ **កំពង់រទេះ** សូមគោរពជូនលោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ ស្នើសុំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ដែលមានភ្ជាប់មកជាមួយនូវ បញ្ជីឈ្មោះ សមាជិកសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនទីកន្លែងនេសាទសហគមន៍ ដើម្បីពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ ។

យើងខ្ញុំគណៈកម្មការសហគមន៍នេសាទ **កំពង់រទេះ** សូមធ្វើការប្តេជ្ញាចិត្ត និងសន្យាដឹកនាំក្នុងការគ្រប់គ្រងសហគមន៍នេសាទដោយគោរពទៅតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ច្បាប់ជលផល និងលិខិតបទដ្ឋាននានា ដែលទាក់ទងនឹងវិស័យជលផល ។

យើងខ្ញុំទទួលខុសត្រូវចំពោះមុខច្បាប់ នូវរាល់កំហុសឆ្គងនៃការអនុវត្តន៍ផ្ទុយពីបទបញ្ញត្តិទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើ សូមលោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ មេត្តាពិនិត្យ និងសម្រេចដើម្បីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ **កំពង់រទេះ** ដោយក្តីអនុគ្រោះ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ៧.ឯកសារផ្សេងៗ
# នៃការបង្កើតសហគមន៍នេសាទកំពង់ទេះ
# ភូមិកំពង់ទេះ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ

| | | |
|---|---|---|
| ឈ្មោះសហគមន៍ | : | កំពង់ទេះ |
| ភូមិ | : | កំពង់ទេះ |
| ឃុំ | : | បឹងចារ |
| ស្រុក | : | សំបូរ |
| ខេត្ត | : | ក្រចេះ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**សូមគោរពជូន**

**លោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ**

**កម្មវត្ថុ** ៖ សំណើរចុះកិច្ចព្រមព្រៀងកន្លែងសហគមន៍នេសាទ **កំពង់រទេះ**។

**យោង** ៖ -អនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែ មីនា ឆ្នាំ ២០០៧។

**លិខិតភ្ជាប់** ៖ កម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងសហគមន៍នេសាទ **កំពង់រទេះ**។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកប្រធានមេត្តាជ្រាបថា សហគមន៍នេសាទ **កំពង់រទេះ** បានបង្កើតឡើងនៅឆ្នាំ ២០០៩ ដោយស្ម័គ្រចិត្ត និងមានគំនិតផ្តួចផ្តើមបង្កើនជីវភាពរស់នៅរបស់ ប្រជា ពលរដ្ឋក្នុងភូមិ **កំពង់រទេះ** ដោយមានការសម្របសម្រួលពីខណ្ឌរដ្ឋបាលជលផលក្រចេះ។ សហគមន៍នេសាទមាន ទីតាំង ស្ថិតនៅ **ភូមិ កំពង់រទេះ ឃុំ បឹងចារ ស្រុកសំបូរ ខេត្តក្រចេះ** មានផ្ទៃក្រឡា ៥២៧ ហិចតា ដឹកនាំដោយគណៈ កម្មការ សហគមន៍នេសាទចំនួន ៩ រូប មានប្រជាជនរស់នៅក្នុងភូមិកំពង់រទេះជាសមាជិក បន្ទាប់ពីបានបង្កើតរួចមក សហគមន៍នេសាទ **កំពង់រទេះ** បានដំណើរការយ៉ាងសស្រាក់សស្រាំ ដោយមានការចូលរួមឧបត្ថម្ភដោយអង្គការអុកស្វាមអូស្ត្រាលី និងគាំទ្រដោយខណ្ឌរដ្ឋបាលជលផលក្រចេះ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងក្រុមប្រឹក្សាឃុំ។ ព្រមជាមួយ នោះគណៈកម្មការសហគមន៍នេសាទ បានរៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីកន្លែងនេសាទសហគមន៍ និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រួចជាស្រេច ហើយនឹងគ្រោងរៀបចំកម្មវិធីចុះ កិច្ចព្រមព្រៀងសហគមន៍នេសាទជាមួយលោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ។

**សូមជូនភ្ជាប់មកជាមួយនូវ** ៖

១-កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

២-ផែនទីកន្លែងនេសាទសហគមន៍មាត្រដ្ឋាន ១/៥០.០០០

៣-បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទ

៤-លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ

៥-សេចក្តីថ្លែងការ នៃការបង្កើតសហគមន៍នេសាទ

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

ធ្វើនៅភូមិ **កំពង់រទេះ** , ថ្ងៃទី.០៣..ខែ.មិថុនា.ឆ្នាំ២០១១

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**ហត្ថលេខា**